# សំណើរសុំការទ្រទ្រង់ និង បទបង្ហាញអំពីគេហទំព័រ៥០០០ឆ្នាំ – www.5000-years.org

ឯកសារព័ត៌មាន

គោរពជូន : សមាគមន៍ធម្មទាននានានៅក្នុងស្រុកនិងក្រៅស្រុក និងពុទ្ធបរិស័ទខ្មែរទូទៅ។

កាលបរិច្ឆេទ : ខែមករា ព. ស ២៥៥៦

គម្រោងដោយ : លោក ស្រុង ចាន់ណា

ទំនាក់ទំនង : លោក ស្រុង ចាន់ណា (ម្ចាស់គេហទំព័រ)
ទូរស័ព្ទ ០១២ ៨៨៧ ៩៨៧

បរិច្ចាគតាម : Acc No. 0001 01 222863 13 (ACLEDA Bank Plc)

Acc Name: SRONG CHANNA (How transfer from oversea)

----- ឬផ្ញើតាម-----------------------------------------

Transfer by: MONEYGRAM / WESTERN UNION

To Mr. SRONG CHANNA (ID.: 010082808)

Email: channasrong@gmail.com

# មាតិកា

## 1 បទបង្ហាញអំពីគេហទំព័រ៥០០០ឆ្នាំ

1.1 ការបង្កើតឡើង

1.2 គោលបំណង

1.3 គោលដៅនិងសកម្មភាព

1.4 គោលជំហរ

1.5 ដំណើរការនិងវិវឌ្ឍភាពរបស់គេហទំព័រ៥០០០ឆ្នាំ

1.6 សេវាបង្ហោះរបស់គេហទំព័រ៥០០០ឆ្នាំ

1.7 ក្រុមការងាររបស់គេហទំព័រ៥០០០ឆ្នាំ

1.8 មធ្យោបាយនៃការផ្សព្វផ្សាយ

1.9 សមិទ្ធិផល និងគម្រោងបន្តបន្ទាប់

## 2 សំណើសុំការទ្រទ្រង់គេហទំព័រ៥០០០ឆ្នាំ

2.1 ហេតុអ្វីត្រូវការប្រកាសសុំការទ្រទ្រង់

2.2 សំណើរសុំការទ្រទ្រង់

2.3 សេចក្តីថ្លែងអំណរគុណ

# បទបង្ហាញអំពីគេហទំព័រ៥០០០ឆ្នាំ

## 1.1 ការបង្កើតឡើង

ព្រះពុទ្ធសាសនា គឺជាពាក្យប្រៀនប្រដៅរបស់ ព្រះសម្មាសម្ពុទ្ធជាម្ចាស់។ ព្រះពុទ្ធសាសនាថេរវាទ ជាការប្រៀនប្រដៅ របស់ព្រឹទ្ធាចារ្យ ឬការប្រៀនប្រដៅជំនាន់ដើម គឺជាការសិក្សាចាស់បំផុត នៃព្រះពុទ្ធសាសនា ដែលនៅគង់វង្សដល់សព្វថ្ងៃនេះ ។ ថេរវាទបានចាប់កំណើត នៅក្នុងអាណាចក្រឥណ្ឌា មានសភាពរក្សាទុកដូចដើម ហើយជាទូទៅប្រហាក់ប្រហែលគ្នា នឹងពុទ្ធសាសនាដំបូង ។ ជាច្រើនសតវត្សរ៍កន្លងមក ព្រះពុទ្ធសាសនាថេរវាទជាសាសនាចំបងនៅក្នុងប្រទេសស្រីលង្កា (៧០ភាគរយនៃចំនួនប្រជាពលរដ្ឋ) ហើយនិងមួយផ្នែកធំនៃអាស៊ីភាគអាគ្នេយ៍ (ប្រទេសខ្មែរ លាវ ភូមា ថៃ) ។ សព្វថ្ងៃនេះ អ្នកកាន់ព្រះពុទ្ធសាសនាថេរវាទ ជុំវិញពិភពលោកមានចំនួនជាង១០០លាននាក់ ហើយក្នុងសតវត្សរ៍ថ្មីនេះ ថេរវាទបានចាក់ឫសក្នុងលោកខាងលិច និងដុះដាលឡើងវិញនៅក្នុងប្រទេសឥណ្ឌា ។

អាស្រ័យដោយមានការគោរពស្រឡាញ់ និងចូលចិត្តចំពោះព្រះពុទ្ធសាសនាជាខ្លាំង និងដោយមានការគាំទ្រទង្វើអំពីក្រុមគ្រួសារផងដែរនោះ ។ ខ្ញុំបាទបានចំណាយពេលវេលាផ្ទាល់ខ្លួនយ៉ាងច្រើនក៏ដូចជាទ្រព្យធនយ៉ាងសមគួរ ដើម្បីរៀបចំធ្វើឲ្យមានឡើងនូវ គេហទំព័រព្រះពុទ្ធសាសនាមួយ ឈ្មោះ "៥០០០ឆ្នាំ"។

គេហទំព័រ៥០០០ឆ្នាំត្រូវបានបង្កើតឡើងនៅខែមិថុនាឆ្នាំ២០១១ ត្រូវនឹង ខែពិសាខ ឆ្នាំថោះ ត្រីស័ក, ព.ស. ២៥៥៥។ មកទល់ពេលនេះមានរយៈពេលជិត ២ឆ្នាំហើយ។ និងដោយមានការអនុញ្ញាតច្បាប់ពី

ក្រសួងធម្មការ និងសាសនា តាមលិខិតលេខ ១២៤/១២ក.ធ.ស.ស.
ស.រ ចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០១២។

## 1.2 គោលបំណង

- ផ្សាយព្រះធម៌តាមប្រព័ន្ធអ៊ីនធឺណែត។
- ពង្រីកចងក្រងឲ្យកាន់តែសម្បូរបែបនៃឯកសារព្រះពុទ្ធសាសនាខ្មែរ តាមបែបបច្ចេកវិទ្យាព័ត៌មានវិទ្យា។
- បន្តុបង្កើនសីលធម៌សង្គម តាមបែបព្រះពុទ្ធសាសនា។

## 1.3 គោលដៅនិងសកម្មភាព

- គេហទំព័រ៥០០០ឆ្នាំបានបង្កើត ក្នុងគោលបំណង ផ្សព្វផ្សាយព្រះធម៌នៃព្រះសម្មាសម្ពុទ្ធ តាមប្រព័ន្ធអ៊ីនធឺណែត ដើម្បីបញ្ជៀបនូវសីលធម៌ចរិយាធម៌ និងសេចក្តីថ្លៃថ្នូរ ទៅដល់ស្រទាប់យុវវ័យនិងពុទ្ធបរិស័ទទូទៅទាំងក្នុងស្រុកនិងក្រៅស្រុក។
- ដើម្បីសម្រួលដល់ការស្តាប់និងសិក្សាព្រះធម៌ឲ្យបានគ្រប់ពេលវេលានិងតាមចំណង់ចិត្តប្រាថ្នាស្រាវជ្រាវរបស់ពុទ្ធបរិស័ទ។
- ស្វែងរក និងបង្កើតបន្ថែមឲ្យកាន់តែសម្បូរបែបនូវប្រភពធនធានថ្មីៗខាងផ្នែកព្រះពុទ្ធសាសនាដូចជាសៀវភៅ (eBooks) សម្លេងការអាន (Audiobooks) ។ល។ ឲ្យទៅតាមបច្ចេកវិទ្យាសម័យថ្មី។
- ជាទិសដៅគឺគេហទំព័រ ចែកចាយប្រភពព្រះធម៌ មានmp3 ព្រះធម៌ជាដើម។ ប្រកាសផ្សព្វផ្សាយតាមគ្រប់មធ្យោបាយ ឲ្យទៅដល់ពុទ្ធបរិស័ទនិងគ្រប់ស្រទាប់យុវវ័យឲ្យបានដឹងនិងបានទទួលយក។

- បង្កលក្ខណៈងាយស្រួលផ្សេងៗ ឲ្យដល់គ្នានិងគ្នាក្នុងការចែកចាយប្រភពព្រះធម៌សម្រាប់ស្តាប់និងសិក្សា តាមបែបសម័យអ៊ីនធឺណែតទំនើប។
- សម្រួលការងារសិក្សាស្រាវជ្រាវសម្រាប់ព្រះសង្ឃនៅក្រៅប្រទេស និងក្នុងប្រទេស ក៏ដូចជាពុទ្ធបរិស័ទទូទៅ។
- បង្កើតនិងពង្រីកឲ្យកាន់តែទូលាយនូវ clip mp3, video អប់រំបែបព្រះពុទ្ធសាសនា ផ្សាយតាមរយៈស្ថានីយ៍វិទ្យុ ទូរទស្សន៍ ដើម្បីឲ្យជ្រួតជ្រាបដល់ប្រជាជនខ្មែរ។

## 1.4 គោលជំហរ

- គេហទំព័រ៥០០០ឆ្នាំមានគោលបំណងតែផ្សាយព្រះធម៌និងចែកចាយប្រភពព្រះធម៌តាមអ៊ីនធឺណែតតែម្យ៉ាងប៉ុណ្ណោះ។ ដើម្បីបង្កភាពរីករាយជ្រះថ្លារបស់ពុទ្ធបរិស័ទដែលបានចូលមក។
- មិនស្វះស្វែងរកប្រាក់ចំណេញ ដោយការប្រើប្រាស់ការផ្សព្វផ្សាយបែបធ្វើជំនួញ តាមរយៈ ការដាក់ផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗលើគេហទំព័រឡើយ។

## 1.5 ដំណើរការនិងវិវឌ្ឍភាពរបស់គេហទំព័រ៥០០០ឆ្នាំ

ដោយហេតុតែខ្ញុំបាទមាននិស្ស័យជាអ្នកស្តាប់នូវព្រះធម៌ជារឿយៗ និងក៏ជាអ្នកប្រមូលផ្តុំទុកនូវmp3 ព្រះធម៌ផងនោះ ។ ម៉្យាងដោយគ្រួសាររបស់ភរិយាខ្ញុំរស់នៅខេត្តបាត់ដំបង ខ្ញុំឧស្សាហ៍ឡើងចុះទៅទីនោះញឹកញាប់ ខ្ញុំបានស្តាប់ឮវិទ្យុមួយឈ្មោះ "វិទ្យុកល្យាណមិត្ត" ដែលតែងតែចាក់ផ្សាយនូវព្រះធម៌សុទ្ធៗគ្រប់ពេល ខ្ញុំមានការស្ញើចសរសើរនូវទង្វើការងារនេះណាស់ ខ្ញុំបានគិតថែមទៀតថាបើមាននៅក្នុងទីក្រុងភ្នំពេញផងមិនដឹងថាល្អយ៉ាងណា ។ នៅក្នុងពុទ្ធ

សករាជ២៥៥៥ (ឆ្នាំ២០១១) ខ្ញុំក៏បានគិតគូសរំាសដើម្បីបង្កើតគេហទំព័រព្រះពុទ្ធសាសនាមួយដែរ ដោយសម្លឹងឃើញថានៅភ្នំពេញមានអ្នកប្រើប្រាស់អ៊ីនធឺណែតច្រើន អាចនឹងផ្តល់ឲ្យពួកគាត់មានលទ្ធភាពនឹងចូលស្តាប់បានងាយ។

- ខ្ញុំក៏បានធ្វើកិច្ចសន្យាជួលមួយ ជាមួយនិងក្រុមហ៊ុន SevingWeb ដើម្បីផ្តល់គម្រោង Website development ឲ្យក្រុមហ៊ុនទទួលធ្វើ។ ការកែសម្រួលចំពោះគេហទំព័រនៅតែបន្តកែសម្រួលរហូតដល់ ចុងឆ្នាំ២០១២ ទើបបានបញ្ចប់ជាមួយក្រុមហ៊ុន ServingWeb ។

- អំពីការប្រមូលចងក្រងប្រភពទិន្នន័យ mp3 និងសៀវភៅធម៌ផ្សេង ។ ខ្ញុំបានចំណាយរយៈពេលជាងមួយឆ្នាំ ដើម្បីស្វែងរកនិងសុំចម្លងដោយផ្ទាល់ពីលោកអ្នកសម្តែងធម៌នានា មានលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស ជាដើម និងតាមរយៈគេហទំព័រផ្សព្វផ្សាយព្រះពុទ្ធសាសនាផ្សេងៗទៀត។

- ខ្ញុំបានប្រើប្រាស់ពេលវេលាយ៉ាងច្រើន ដើម្បីធ្វើការ covert mp3 files ក្នុងការសម្រួលឲ្យបានល្អឡើងវិញ រួមនិងការកែតម្រូវ Pdf files និងរៀបចំទុកដាក់ឲ្យមានរបៀបរៀបរយតាមប្រភេទអាល់ប៊ុមនីមួយៗតាមរយៈប្រព័ន្ធកុំព្យូទ័រ ដើម្បីងាយមើលយល់និងស្វែងរក។

## 1.6 <u>សោហ៊ុយផ្សព្វផ្សាយរបស់គេហទំព័រ៥០០០ឆ្នាំ</u>

ដើមឡើយ ការចំណាយថ្លៃបង្ហោះផ្សាយគេហទំព័រ៥០០០ឆ្នាំ តែ ១០០ ដុល្លារប៉ុណ្ណោះ ក្នុងមួយឆ្នាំ។ ប៉ុន្តែដោយសារគំហុកនៃការចុចចូលទ

ស្សនា/ស្តាប់ កើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ រួមទាំងបញ្ហាបច្ចេកទេសផង នោះ គេហទំព័រ៥០០០ឆ្នាំបានប្តូរ Server Hosting សេវាបង្ហោះជាញឹកញាប់ ។ ម៉្យាងដើម្បីធ្វើឲ្យមានលទ្ធភាពទទួលការចូលមកនៃអ្នកទស្សនា/ស្តាប់ឲ្យកាន់តែច្រើននិងមានសេរីភាពក្នុងទាញយកឯកសារនៅលើគេហទំព័រ ទើបទាមទារឲ្យគេហទំព័រ៥០០០ឆ្នាំត្រូវការម៉ាស៊ីនបង្ហោះមួយដែលមានសមត្ថភាពខ្ពស់។ ខាងក្រោមនេះ ជាបរិច្ឆេទនៃការផ្លាស់ប្តូរកន្លងមកៈ

- បង្ហោះតាមរយៈក្រុមហ៊ុន ServingWeb (ភ្នំពេញ)
  ខែ មិថុនា ឆ្នាំ២០១១- ខែកញ្ញា ឆ្នាំ ២០១២ (បង់ ១០០ដុល្លារ/ឆ្នាំ)
  ខែតុលា ឆ្នាំ២០១២- ខែធ្នូ ឆ្នាំ ២០១២ (បង់ ១០០ដុល្លារ/ខែ)

- បច្ចុប្បន្នបង្ហោះតាមរយៈក្រុមហ៊ុន Hostgator (សហរដ្ឋអាមេរិក)
  ខែមករា ឆ្នាំ២០១៣- បច្ចុប្បន្ន (បង់ ១៧៦ដុល្លារ/ខែ)

បច្ចុប្បន្នភាព នៃការចំណាយថ្លៃបង្ហោះរបស់គេហទំព័រ៥០០០ឆ្នាំ កាន់តែខ្ពស់ទៅៗ ដោយហេតុថា លំហូរនៃអ្នកចូលស្តាប់/ទាញយកឯកសារ កាន់តែច្រើនឡើងៗ ពីមួយថ្ងៃទៅមួយថ្ងៃ ។ ឯទំហំផ្ទុករបស់គេហទំព័រមានទំហំធំរហូតដល់ជិត 300GB ដែលធ្វើឲ្យមានការលំបាកផ្ទេរ និងថែទាំៗ អ៊ីចឹងហើយ ទើបខ្ញុំសម្រេចជួលផ្តាច់នូវម៉ាស៊ីនបង្ហោះមួយដាច់តែឯង ដើម្បីសម្រួលការណ៍ទាំងអស់នេះៗ

## 1.7 ក្រុមការងាររបស់គេហទំព័រ៥០០០ឆ្នាំ

តាំងអំពីដើមរៀងមករហូតដល់សព្វថ្ងៃនេះ ៥០០០ឆ្នាំពុំទាន់មានក្រុមការងារ ដើម្បីសម្រួលការងារផ្សេងៗនៅលើគេហទំព័រនៅឡើយ។ ដោយមានតែខ្ញុំបាទម្នាក់ឯងមើលលើការងារនេះ ទើបមិនអាចធ្វើឲ្យបានរលូននិងរហ័សឡើយ។

## 1.8 មធ្យោបាយនៃការផ្សព្វផ្សាយ៥០០០ឆ្នាំ

មូលហេតុដោយថវិការចំណាយមានការកំណត់ គេហទំព័រ៥០០០ឆ្នាំ ពុំអាចនឹងមានលទ្ធភាពផ្សព្វផ្សាយខ្លួនតាមរយៈប្រព័ន្ធផ្សព្វផ្សាយធំៗបានឡើយ។ តែទោះជាយ៉ាងណាក៏ គេហទំព័រ៥០០០ឆ្នាំ បានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយមួយចំនួនដែលមានប្រសិទ្ធភាពផងដែរ ដូចជា៖

- ប្រព័ន្ធផ្សព្វផ្សាយសង្គម Facebook, Twitter, Email..
- ស្វែងរកការសហការល្អរវាងដៃគូផ្សព្វផ្សាយគេហទំព័រផ្សេងៗ
- ស្វែងរកការសហការល្អក្នុងភាពជាអ្នកផ្សព្វផ្សាយព្រះពុទ្ធសាសនាដូចគ្នាជាមួយស្ថានីយ៍វិទ្យុកល្យាណមិត្ត (បាត់ដំបង), ស្ថានីយ៍វិទ្យុព្រះពុទ្ធសាសនាកម្ពុជរដ្ឋ (សៀមរាប) ។ល។
- បង្កើតកម្មវិធីគ្រប់គ្រងអាល់ប៊ុមព្រះធម៌ និងប្រកាសអញ្ជើញពុទ្ធបរិស័ទឲ្យមកចម្លងដោយផ្ទាល់ពីគេហទំព័រ៥០០០ឆ្នាំ។
- បង្កើតការសហការល្អរវាងញាតិព្រះធម៌ និងបង្កើតទីតាំងសម្រាប់ចម្លងព្រះធម៌កាន់តែច្រើននៅទូទាំងប្រទេស និងបរទេស។

## 1.9 សមិទ្ធិផល និងគម្រោងបន្តបន្ទាប់

- សរុបអ្នកចូលទស្សនា/ស្តាប់ និងអ្នកទាញយក
  - ✓ បច្ចុប្បន្ននេះ គេហទំព័រ៥០០០ឆ្នាំមានអ្នកចូលជាមធ្យមចំនួន ២០០០-៤០០០នាក់ក្នុងមួយថ្ងៃ
  - ✓ និងចុចស្តាប់ចំនួន ជាង២សែនដង ក្នុងមួយថ្ងៃ
  - ✓ រួមទាំងការទាញយកឯកសារពីគេហទំព័រ ចំនួន 500GB-1500GB ក្នុងមួយថ្ងៃ។

- ការផ្សារស្កានព្រះត្រៃបិដក
  - ✓ ៥០០០ឆ្នាំ ដោយមានការជួយជ្រោមជ្រែងអំពីឧបាសិកា កាំង ហ្គិចណៃ និងពុទ្ធបរិស័ទផ្សេងៗ បានប្រើប្រាស់ពេលវេលា ជាង៤ខែ ហើយបានសម្រេចការផ្សារស្កានព្រះត្រៃបិដកថ្មី ដែលធ្វើឲ្យមានការងាយស្រួលប្រើប្រាស់តាមរយៈកុំព្យូទ័រនិង ឧបករណ៍អានអេឡិត្រូនិចផ្សេងទៀត។ នេះគឺជាការបើកទំព័រ សករាជថ្មីសម្រាប់ពុទ្ធបរិស័ទខ្មែរយើង ដែលអាចអានគម្ពីរ ព្រះត្រៃបិដកតាមបែបបច្ចេកវិទ្យាសម័យថ្មី។

- ការបង្កើតកម្មវិធី៥០០០ឆ្នាំ សម្រាប់ប្រព័ន្ធWindows គ្រប់គ្រងអាល់ប៊ុម ព្រះធម៌
  - ✓ កម្មវិធីនេះមានមុខងារជាច្រើនដែលនឹងសម្រួលដល់ការសិក្សា របស់ពុទ្ធបរិស័ទតាមបែបលក្ខណៈកុំព្យូទ័រទំនើប។

- ការផ្សាយចែកចាយផ្ទាល់ និងបង្កើតសាខាចែកចាយ
  - ✓ ដោយមានការចូលរួមល្អក្នុងទិសដៅតែមួយគឺផ្សព្វផ្សាយព្រះធម៌នៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ របស់ញាតិព្រះធម៌។ គេហទំព័រ៥០០០ឆ្នាំ បានរៀបចំពង្រីកទីតាំង ដើម្បីផ្តល់លទ្ធភាពដល់ពុទ្ធបរិស័ទបានចម្លងmp3 ព្រះធម៌ងាយស្រួល។

- គម្រោងបន្តបន្ទាប់របស់គេហទំព័រ៥០០០ឆ្នាំ
  - ✓ ខណៈពេលនេះ ដោយសារខ្ញុំបាទមានតែម្នាក់ឯង ពុំអាចនឹងធ្វើឲ្យមានការរហ័ស, ស្ថេរភាពនៃគេហទំព័របាន ដូច្នេះខ្ញុំបាទនឹងមានគម្រោងត្រូវការៈ
    - បន្ថែមអ្នកគ្រប់គ្រងទិន្នន័យ (បុគ្គលិក)
    - និងការលំហែទាំ បន្ទាន់សម័យគេហទំព័រប្រចាំខែ
    - Upgrade SERVER និងការស្វែងរកការទ្រទ្រង់ច្បាស់លាស់ ។

# សំណើសុំការទ្រទ្រង់គេហទំព័រ៥០០០ឆ្នាំ

## 2.1 ហេតុអ្វីត្រូវការប្រកាសស្វែងរកការទ្រទ្រង់

- ដើម្បីរក្សាឲ្យបាននូវស្ថេរភាពនៃការផ្សាយព្រះធម៌តាមរយៈគេហទំព័រ៥០០០ឆ្នាំ ក៏ដូចជាសម្រួលរាល់ថ្ងៃចំណាយបង្ហោះ ដែលពេលនេះ៥០០០ឆ្នាំអាចទ្រទ្រង់យ៉ាងយូរត្រឹម ខែឧសភា ឆ្នាំ២០១៣ប៉ុណ្ណោះ។
- ដើម្បីបម្រើតម្រូវការចូលស្តាប់នៃពុទ្ធបរិស័ទ នូវចំនួនច្រើនៗនាក់ និងសេរីភាពនៃការទាញយកឯកសារនានាពីគេហទំព័រ។
- ដើម្បីនឹងសម្រេចគោលដៅផ្សេងៗទៀត ដែលពុំទាន់បានធ្វើនិងសម្រេចបាន។

## 2.2 សំណើរសុំការទ្រទ្រង់

យោងតាមបទបង្ហាញ និងប្រកាសអំពីគោលដៅរបស់គេហទំព័រ៥០០០ឆ្នាំខាងលើនេះ ។ ខ្ញុំបាទសូមទាញចំណាប់អារម្មណ៍របស់ លោកអ្នក, និងស្ថាបនិកសមាគមន៍ធម្មទាននានា ដើម្បីបានជាការចូលរួមចំណែកនូវការផ្សព្វផ្សាយព្រះធម៌របស់គេហទំព័រ៥០០០ឆ្នាំ ក៏ដូចជាសម្រាប់ ជាបុណ្យកុសលក្នុងកិច្ចការធម្មទាននេះ។

ខ្ញុំបាទ រំពឹងទុកអំពីការយោគយល់ដោយសុទ្ធចិត្តអំពីលោកអ្នកមកលើគេហទំព័រ ៥០០០ឆ្នាំ, អំពីចិត្តជាសទ្ធាជ្រះថ្លាយ៉ាងមុតមាំលើព្រះពុទ្ធសាសនា និងដើម្បីផ្សព្វផ្សាយព្រះពុទ្ធសាសនាតទៅ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងទូរស័ព្ទលេខ: ៨៥៥ ១២ ៨៨៧ ៩៨៧

## សូមចូលរួមបរិច្ចាគមកកាន់គេហទំព័រ៥០០០ឆ្នាំតាមរយៈ៖

ខ្ញុំបាទ ស្រុងចាន់ណា

Acc No. 0001 01 222863 13 (ACLEDA Bank Plc)

Acc Name: SRONG CHANNA (How transfer from oversea)

----- ឬផ្ញើតាម---------------------------------------

Transfer by: MONEYGRAM / WESTERN UNION

To Mr. SRONG CHANNA (ID.: 010082808)

Email: channasrong@gmail.com

H/P: 855 12 887 987

### 2.3 សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណលោកអ្នក, ស្ថាបនិកសមាគមន៍ធម្មទាននានាដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នកដើម្បីធ្វើការអាន និងឈ្វេងយល់អំពីគេហទំព័រ៥០០០ឆ្នាំ តាមរយៈអត្ថបទនេះ។

សូមលោកអ្នកអនុមោទនានិងសម្រេចបាននូវបុណ្យទាំងឡាយជាមួយខ្ញុំបាទបានធ្វើហើយតាមរយៈការផ្សាយព្រះធម៌លើគេហទំព័រ៥០០០ឆ្នាំ។

# សូមអរគុណ